# ននៀង់សែ ប៉ាណូស គោ់ រុីស សឹត



# រឿងមនុស្សស្លាប់ហើយរស់វិញ


រៀបរៀងដោយ ៖ លោក ធៀង សារឿន

រូបភាពដោយ ៖ លោក ពុន ទូញ



From the People of Japan

អង្គការ សហការ

ICC

ទ០០៥អស

សើគ ពែ ទី អង់កាន់ រ៉ូះ ពៀរ ដូវ ជៀក ចាង៍ គួប អន់ឌែ ។ អន់ឌែ ចាក ប៉ាគ់ចំ កា អន់ឌូ ឡាំ ប៉ាគ់ចំ កា អន់ឌូ ។ ទី ដារ់ ម៉ោញ ណោះ អន់ឌែ ពៀរ ដូវ ឡាំ ណាំង រ៉ាម៉េះ ប៉ាគ់ ព្រី ប៉ាត្រឹង អូបុន អូ សំឡាង អន់ឌែ ដារ់ ណោះ ចាង៍ អែ



ប៉ះ រ៉ាម៉េះ តាព្លៀស ឡឹង អ្លឹង ប៉ុពូ ចោះ ជុង អែ ទៅ ចប់ តាប់ សូង៍ ឡាច់ ផាម អៀង កាខាក់ ។ ផាឌី ម៉ោញទ្រុ ឡឹង ណោះ កាតាច់ កាសែ តាំងហើម តោ៍ កាអែ សៀប ហះ ចារ រ៉ាម៉េះ ណោះ ហាង ។





ចាង៍ អ៊ែ កា ទី កាន អុក ពុត កាខាក់ ញុាំ អង់ហ្យាំង ឡាច់ អូ បុិច សង់ អូ បុិច សា វុាំបីស កា អន់ឌែ ឡាប៍ អ្វៃ ឡាប៍ ចំប៊ិង អន់ឌូ ឡឹង ចិ ឡឹង ស្វា ។ ផាឱ ទុញ មុាំង ក្លាំងដារ់ ឡឹង ណោះ ត្រគ់ ផះ ថុន ពៀ ទុំ ចាង៍ អ៊ែ អ្វៃ វុិស ណោះ កា ឡាំ មុីរ ឡាំ ស្រ៊ែ ទ្រុះ អន់តើប ទ្រុះ ប្រៃហល ។ កេះ តារ៍ អន់ទ្រឹល តារ៍ ញ៉ា អ៊ែ កា ម៉ុត តឹម ប៉ើក ប៉ាកូះ អុញ ភឿ អន់ ប៉្រះ៍ ពៀ ប៉្រះ៍ ភែ ឡាំ ទម ឡាំ អញ់ជួរ លូ អូ អន់ សៃម អ្យាំ អន់ទៀគៗ

ម៉ុត ពឹង ម៉ុរ ណោះ ណឹង ។  អ្វៃ កាអ៊ែ កាណុង
ប៉ើក ណោះ ម៉ោញ ដួវ អ៊ែ  ងែ ឡ្វាងែ  ង៉ ឡ្វាង៉
ឡ្វាង៉ាន់ ឡ្វាង៉ោះ  ឡ្វាំងវ៉ាគ់ ព្រី  ឡ្វាំងវ៉ាគ់ ទៀក
កាតាំង ដឹង ប៉ានឹរ សៃម តេះ ពឹង ព្រី វ៉ាជែវ ម៉ាមែវ
ទ្វៃឡងណោះ អ៊ែ កាតាំង អន់តើប ប៉ាក៍ សាមៀយ
តេះ ហះ អន់ទ្រឹល ម៉ុរ គូ ៗ ។

កាតាំង អន់តើប តេះ នីណោះ៍ អ៊ែ៍ កា ហ៊ែង៍ រុំបីស ហ៊ែង៍ ឡិ ឈូស ស្រូគៗ ចាជ្រែប៍ កា ឡាកោ អ៊ែ៍ អ្វៃ ម៉ោញ ដូវ ម៉ោញ ឌែន៍ អូទី គួប អូទី គ្រៀ ។

អ៊ែ៍ ផា ៖ «ហឺ វេ ! យ៉ាគ់ អន់តើប កាតាំង អឹស តេះ នីណោះ៍ រ៉គ់ ប៉ប៍ ចាង៍ អាញ់ រ៉គ់ អ្វៃ ចាង៍ អាញ់ រ៉គ ញឹនអ្វៃ រ៉ល រ៉គ ញឹនអ្វៃ កាកឹក អន់ឌូ »



ចាជ្រែប សឹត ចាជ្រែប  អូ ដាម៍ ប៉ាខត់ ពុត  អ៊ែ កា ទ្បាច់ ទៀក ម៉ាត់ ព្រិៗ តាំងហាត់ ពួយ មែង ។  អ៊ែ ញ៉ាំ អន់ដើរ កាប អន់ដើរ ផា៖ «ហឺ វេ ! អាញ់ ញ៉ា ប៉ិច កើត ប៉ាឈូស  ញ៉ា ប៉ិច កើត ប៉ាណា  តាទ្បាម៍ កាថុក  តាទ្បាម៍ កា ញ៉ាក នីអៀ  អូទី អុះ អូទី ម៉ី  អ្វែ ង៉ក់ ទ្បាង៉ក់ ម៉ោញ ដូវ  ង៉ូវ ទ្បាង៉ូវ ម៉ោញ ឌែន អូទី គួប ចំបឹង អូទី គួប រ៉ះ សារ » ។



ស្រាប់ រាំបីស ស្រាប់ កាចាំង អ៊ែ កា អ្យូវ ការីន កាស៊ែ រៅ កា ចឹង ញ៉ាក់ ផាឌី ញ៉ាក់ កាអ៊ែ នីចម័ កា កាង័ ញ៉ាក់ នីចម័ កា អូ ដាម័ កាង័ ឃឺ ពូ ចឹក ឃឺ ពូ ប៉ាន់តឹង ហាង រៅ ណោះ ។ អ៊ែ ផា៖ «បះ រ៉ាយ ពឿ ដេ ប្រ៉ែគ័ ប៉ាឡៃវ ប្រ៉ែគ័ ប៉ាញ់សាំង អា វេស អំប៉ុង អាញ់ អ្វៃ ថុក អ្វៃ ញ៉ាក ម៉ោញ ដូវ ម៉ោញ ឌែន ប្រ៉ែគ័ មឹនតឹម ឡាំ នីអៀ ណាគ្ន »



ប៉ាគ់ អ៊ែ ឡ្បាំ ហៃ ទីល ប៉ាគ់ ណោះ ផាឱ ប៉ប័ ចាង័
អ៊ែ ផះ អ្វៃ ចឹក ប៉ាន់តឹង វៅ ។ អ៊ែ ផា៖ « ចាង័
ដេល អា ពែ ! ណោះ ហាង កាង័ អាញ់ ញ៉ាក់ អំពែ
ពែ ស្ប៊ូ កា អីស ចឹក ប៉ាន់តឹង ។ ញ៉ា អីស អ្វៃ ប្រ៉គ័
ហះ អា ចាង័ ? ពិ សឹត វ៉ាឡ្បូវ ប៉ាគ់ ប៉ើក តោ ! ដាគ់
កេះ អីស រ៉ីស សឹត អា ! អាញ់ ម៉ាគ់ ឡ្បាងត កាអីស
កាខាក់ ឡ្បាច់ អ្វូ ប៉ិច សង់ អ្វូ ប៉ិច សា អ្វៃ អ្វូ សាំ
តៃប អ្វូ ហ្លាក់ » ។ ចាង័ អ៊ែ រ៉ីស សឹត ណោះ កា
ឡ្បុកឡ្បាយ លូ ញុាំ អញ់ស្រំ លូ កាប ផា៖



« អាញ់ កា ឡាងត កា អីស នីទៅ ដេល ចាង» ។ ឡៃឡងណោះ អន់ឌៃ គ្វែត អន់ឌៃ អន់ដើរ ញ៉ាំ អន់ដើរ កេះណោះ សឹត អៃ្វ កា អន់ឌៃ ប៉ាគ់ ប៉ើក រ៉ះ សារ គ្រិកៗ ម៉ោញ ណាំង សី ម៉ោញ ម៉ោញ ណាំង សី ម៉ោញ រ៉ល់ អន់ដើរ កាកឹក អន់ដើរ ដាគ់ រ៉ាញ៉ិក រ៉ាជថ ។

បាគ់ មង កាង៉ាច ដារ់ ចិរៗ អ៊ែ កា ជៀក ចាង អ៊ែ ណោះ សឹត ប៉ាគ់ ហី ។



ចាង៉ អ៊ែ ផា៖ « សឹត ដឹង អីស ពិ ចាង៉ ! អាញ់ៗ អ្វៃ ហះ អា ហាង អាញ់ » កាតាំង ចាង៉ អ៊ែ ផា នីណោះ៉ អ៊ែ កា អ្វូ ប៉ុងខំ ដេល ។ កេះណោះ អ៊ែ ផា៖ « ផាណោះ៉ អាញ់ សឹត អ្លាត អីស ហាង ចាង៉ ! ដាវ់ យ៉ាង៉ អីស ឡ្ញាំ ចាចាក ប៉ាគ់ អា ណាគ្វ ហោគ ! » ចាង៉ ប៉ាទ្រូ តើល <អ៊ុំះ> ។ ទ្វៃឡងណោះ សឹត កាអ៊ែ ទុត អន់ទុត ទឹល ប៉ាគ់ ហី ទឹល ប៉ាគ់ ក្រាន តាទិច ។



កេះណោះ អ៊ែ ឡ្ញាំ ៉ះ កា ពឹ ម៉ៃគ ប៉ាទ្រ្វ ផា ៖ «ហៃស ដារ់ អា អាញ់ ប៉ប័ ចាង៍ !» ពឹ ម៉ៃគ ប៉ាទ្រ្វ ផា ៖ « កាប ឡ្វិគ័ឡ្វាគ័ អីស អា ! ឡ្វឹង ប៉ាសេីគ បេី កាតាំង លៅ អាញ់ ប៉ាណូស តោ័ អ្លុរ៉ុស សឹត» ។ អ៊ែ ផា ៖ «ដាគ់ អង់កេះ អន់ជីស អូស្សឿ ញ៉ឹន ម៉ាគ់ អ្វៃ អន់ឌូ អ៊ែ ណាំង សី អាញ់ អាញ់ ណាំង សី អ៊ែ កេះ ណោះ ៉ល់ កាកឹក គួប ញ៉ឹន ៉គ់ កាខាក់ ។

ផា អន់ដីស អូ សឿ កូម័ ដារ់ យ៉ាង័ ទៀ  អាញ់ ចឹង ជៀក អ៊ែ តូវ័ ប៉ាណាល អញ់ជុ កេះណោះ អ្យក់ សឹត ប៉ាគ់ ហី អន់ កា អន់ដីស ហៃ ។



តារ កាំលី អ៊ែ កា ឡ្យាំ ម៊ីរ ណាគ្ន ។ ចាង័ អ៊ែ ណោះ កា ឡ្យាំ ចាចាក ណាគ្ន ដេល ។  អ្វៃ កា អន់ឌែ ៉រះ សារ ប្រេហីយ្គ តាប្រេហីយ្គ ប្រាក់ តាប្រាក់ ឡៃ្យងណោះ ចាង័ ប៉ាណ្យូស ផា ៖ « ពិ ចាង័ តូវ័ ប៉ាណាល អញ់ជុ ពិន ចាង័? » ចាង័ ប៉ាទ្រូ  ផា៖

« ញ៉ា ចឹង តូវ៉ ចាង៉ កា ណោះ ចាង៉ ? ចាង៉ ប៉ាណូស
តើល ផា៖ «តូវ៉ កា អាញ់ ប៉ិច ក្យាគ់ ប៉ាដក់ ក្យាគ់ ប៉ាជៀ
អឹស ចាង៉ ! ខង អឹស អូ ថៃ សឹត ប៉ាគ់ ហី ។ ផា អាញ់
ប៉ប៉ ប៉ាណាល អញ់ជុ អឹស អា សាម៉ើ កា អាញ់ ប៉ប៉ អឹស
កេះ» ។ កាតាំង អ៊ែ ផា នីណោះ៉ ចាង៉ អ៊ែ កា ភម តូវ៉
តាទិច ។ បគ៉ កាង៉ាច អ៊ែ កា ជៀក ចាង៉ អ៊ែ សឹត ណាគ្ន
ហះកា ចាង៉ អ៊ែ អូ ថៃ សឹត សា អ្វះ ។ ទ្វៀងណោះ អ៊ែ កា
សឹត ម៉ោញ ដូវ អ៊ែ ណាគ្ន ។



បត៍ ទឹល ប៉ាត់ ហី អ៊ែ កា អ្យក់ ប៉ាណាល អញ៉ូជុ ណោះ ឡ្សាំ តាំបាង កា ពី ម៉ែត ចាង៍ អ៊ែ ។ បត៍ អ្លុ អន់តត់ ផា ប៉ាណាល អញ៉ូជុ គន អន់ឌៃ អន់ឌៃ កា សឿ តាទិច ។ កេះណោះ អន់ឌៃ ផា ៖ «ញ៉ោ អីស អូ ជៀក អ៊ែ សឹត ប៉ាត់ ហី លូ អីស សោ ?» អ៊ែ ផា ៖ « អាញ៉ូ ជៀក ដេល ទឹល អ៊ែ អូ ថៃ សឹត អូ ថៃ ចាក នីចម៍ ឡ្សត់ អាញ៉ូ ចឹង ប្រ៉ត៍ វត៍ ?» ។



ពឹ ម៉ែគ ប៉ាទ្រូ ណោះ ផា៖ « ផាណោះ៍ ដារ់ យ៉ាង៍  អ៊ីស ប៉ាយ ពរ សាំងអ៊ឹត អន់ ពីកៗ ហោគ សោ ! ញ៊ឹន ចឹង ឡ្វាំ អន់តីគ ។  ផាឱី តារ កាំលឺ ឡ្វាំ កាអ៊ែ ប៉ាគ់ ម៉ុីរ ណាគ្គ ហាង ចាង៍ អ៊ែ ណោះ ផាឱី ទឹល ប៉ាគ់ ម៉ីរ ប៉ាយ កាអ៊ែ ពរ សាំងអ៊ឹត ពីក ឡ្វាន់តៃរ ។



បគ័ ទឹល ប៉ាគ់ ម៉ុីរ ពឹ ម៉ៃគ ចាង័ អ៊ែ ណោះ ម៉ុត អោន ទិ ហះ គុល ពៀ ។ ផាឌី ម៉ោញទ្រុ ឡ្ទឹង ណោះ ប៉ាឈួស តោ័ វ៉ុីសសឹត ណោះ កា ឡ្ទាំ ចាក ង៉ោយ វ៉ះ សារ ប៉ាគ់ ប៉ើុក ចាង័ អ៊ែ ណាគ្ន ។ អ្វៃ កា អន់ខ៊ែ វ៉ះ សារ គ្រិកៗ ម៉ោញ ណាំង សី ម៉ោញ ម៉ោញ ណាំង សី ម៉ោញ ឡ្ទាក់កា ដាវ់ តាំងហៀ ៗ ដេល ។ ប៉ប័ នីណោះ័ ពឹ ម៉ៃគ អ៊ែ ទ្រង អា កា ហោក កា ខាក់ ។



ឡៃងណោះ អន់ឌែ ក្លោ កាម៉ាញ់ ណោះ កា ប៉ាច ពរ សាំងអ៊ឹត ពឹង អំប៉ាង តី កេះណោះ ម៉ុត តឹម ប៉ើក ចាំងហ្វាត រ៉ុប គន អន់ឌែ ណោះ ប្យ៉ុប ពឹង សក់ ។ គន អ៊ែ សំប៉ត់ នីចម័ កា អ្វូ ដាម័ សាន់ទ្រៀន នីចម័ កា អ្វូ តាប្លឹច អុះ កា ពរ សាំងអ៊ឹត តឹត ពឹង សក់ អ៊ែ ។ ពឹ ម៉ែគ អ៊ែ ផា ៖ «ហឺ គន ដាគ់ កេះ  អីស រ៉ុស សឹត ណាគ្ន នីអៀ  ញ្ញឹន ម៉ាគ់ ថឹច កា អីស ឡ្បាច់ អ្វូ ប៊ុច សង់ អ្វូ ប៊ុច សា ។



គន អ៊ែ ផា៖ «អាញ់ កា ឡាងត កា អន់ជីសនីទៅ ដេល ។ អាញ់ ចឹង សឹត ប៉ាគ់ ហី អាញ់ អ្យូគ កា អន់ជីស អ្វូ អត់ សំរ៉ាញ៉ អ្វូ អត់ ពុត កា អាញ់ ។ ផា អន់ជីស តះ ប៉ាស្យាប កាប តាតំ អើ ប៉ាទ្រូ អើ អំហ្មោច កា អាញ់ អាញ់ តោ៉ កេះ ប៉ាទ្រូ កេះ ប៉ាត្រាច៉ រ៉ាយ៉ស៉ ហាង អន់ជីស អ្វូ ប៉ប៉ កេះ អាញ់ ឡាក់កា អា ណាក្ត » ។ ពី ម៉ៃគ អ៊ែ ផា៖ «ជក់កា អីស ចៃ សឹត ប៉ាគ់ ហី គន ញ៉ឹន ឡាប់ ផា អ្វូកាប នីណោះ៉ អុះ ទឹល អីស រ៉ះ កេះ អា » ។

កេះ រ៉ះ សារ  រ៉ះ កាឌី  អន់ឌែ កា សឹត ប៉ាគ់ ហី ទិ
អន់ឌែ ត្រែងៗ ។

ប៉ាណូស តោ័ ណោះ ដាគ់ ថិ ប្រាងៗ កាតាង
ប្រែើៗ កាឌែ ត្រគ់ ត្រង័  បាក ឡាន់ថ្វាំ ឡាយ៉ាម័ ឡឹង
ពូ ។ អ៊ែ អ្វៃ ប៉ាគ់ ស្រុក អូទី លូ ម៉ោញ្ញ សាណាំ ផាឌី ទី
តាតាម័ កាណុង ស្រុក ណោះ  ម៉ោញ្ញ ដួវ  ប៉័រ ទី ប៉័រ
រង អ៊ែ ប្រ៉ែគ័ គន ប្រ៉ែគ័ កាម៉ាញ់្ញ ។ ញ្ញន កា ប៊ុច តាឡាម័
កាម៉ាក័ ណោះ កា ឡាំ ប៉័រ ទឹល ប៉ាគ់ ពឹ ម៉ៃគ អង់កាន់
បគ័ ទឹល ប៉ាគ់ ណោះ អ៊ែ កាប ប៉ាញ់្ញជៀរ ផា ៖

«អឺ វគ័ ! អឺ យ៉ាគ់ ! អាញ់ ផា ប៊ិច ប៉់រ អ្វៃ ប៉់រ កោប លូ អន់ដីស នីចម័ អន់ដីស ចឹង ផា កា អាញ់ អា ?» ពី ម៉ៃគ អង់កាន់ ណោះ ផា ៖ «ហឺ សោ ! ញ៉ា ចឹង យច កា ប៉់រ ទី ប៉់រ វង គន ញឹន អា សោ ! ញឹន អា អូ រើស កា អង់ អូ សាណង់ កា ម៉ាយ អ៊ុះ ដឹង កា នីអៀ សោ : ផា អីស ប៊ិច កា អ៊ែ ចៃ កាអ៊ែ តាទិច អីស តង កាតត់ ពុត អត់ ប៉ានឹរ ជែ កាប អូ ដាគ់ អូ ឡាយ៉ាម័ លូ ជែ អើ ប៉ាទ្រូ អើ ប៉ាត្រាច័ កា អ៊ែ ដៃស» ។



ខង អ៊ែ អា អូ ត្រគ់ ឡាក់កា ប៉ាឈូស ពិន អុះ ផា អីស អើ ប៉ាទ្រូ កា អ៊ែ ដារ់ ចំ អ៊ែ ចឹង តៅ៍ ដារ់ ណោះ ហង» ។ កាម៉ាក៍ ណោះ ផា ៖ « ដក់កា អន់ជីស ភម អន់ អាញ់ ទី អាញ់ ឡាប់ អូ អើ ប៉ាទ្រូ អូ អើ ប៉ាត្រាច៍ កាអ៊ែ អុះ  ទឹល អាញ់ អ្លុ អន់តគ់ កេះ អា » ។ ហៃ កាអ៊ែ ឡាប់ នីណោះ៍ ពឹ ម៉ៃគ អង់កាន់ ណោះ កា អន់ អន់ឌែ ទី គួប អន់ឌែ តាទិច ។



ទុញ ម៉ាំង ក្លាំងដារ់ ឡឹង ណោះ អន់ខែ កា ទី គន អង់កាន់ ម៉ោញ ដូវ ។ ប៉ាត្រឹង ដារ់ ណោះ កាម៉ាញ់ អ៊ែ ជឹរ ហុំ ទុញ កា ខាក់  គន អ៊ែ ទ្រង ហី អា កា ញ៉ាំ ខរ់ អូ សុប អូ ញ៉ោ ។  ក្លោ អ៊ែ ប៉ាឡោម អន់ដើរ អើ អន់ដើរ សាអ្វះ អូប៉ប័ អ៊ែ ហាវ ។



ឡែង ណោះ  អ៊ែ អូ អត់ សំរ៉ាញ័  ផាឪ តាព្លៀស ប៉ានឹរ ពឹរ កាង ផា៖ « បះ នីអៀ តាទិច ទី កាម៉ាញ់ ប៉ាទ្រូ  ទី កាម៉ាញ់ ប៉ាត្រាច័ វេស អូ ត្រគ់ ឡាក់កា ប៉ាឈូស ឡាក់កា ប៉ាណា ។  បគ័ អ៊ែ ផា នីណោះ័ កាម៉ាញ់ អ៊ែ ហាវ ឡឹង ហុំ  ទឹល ប៉ាគ់ ហី  តៅ័ សាតឹល កេះ ប៉ាទ្រូ រ៉ាយ៉ស័ ។ អៃ



សល់ ដឹង ក្លោ អ៊ែ លូ គន អង់កាន់ អ៊ែ ម៉ោញ ដូវ ។ ពូ អន់ សិច គន អ៊ែ ណោះ ផា ផូង័ ខ្លោង ប៉ាទ្រូ ទឹល រុាំង ហាវ ពិន កិញ អៀ ៕

# រឿងមនុស្សស្លាប់ហើយរស់វិញ

កាលពីព្រេងនាយ មានស្រីក្រមុំពីរនាក់ជាមិត្តសម្លាញ់នឹងគ្នា ។ ពេលទៅណាមកណា ពួកគេមិនដែលបែកគ្នាឡើយ ។ មានថ្ងៃមួយនោះ ពួកគេបានបបួលគ្នាទៅរកអុសនៅក្នុងព្រៃតែពីរនាក់ ។ ជាអកុសលអី សម្លាញ់ម្នាក់នោះ បានពុះអុស ផ្លាតពីឈើត្រូវជើងខ្លួនឯង រយះសាច់ប៉ុនមុខដឹងបណ្ដោលអោយមានឈាមហូរច្រើន ។ ពេលអស់ឈាម នាងនោះក៏ដាច់ខ្យល់ស្លាប់នៅកន្លែងនោះមួយរំពេច ។ ចំណែកនាងម្នាក់ទៀតបានយំសោកបោកខ្លួន ភ្លេចបាយភ្លេចទឹក នឹកអាណិតស្រណោះ អាលោះអាល័យដល់សម្លាញ់ដែលធ្លាប់រស់នៅរួមទុក្ខរួមសុខជាមួយគ្នាតាំងពីតូចៗមកម្លេះ ។ តែពេលនេះ ព្រហ្មលិខិតបានតម្រូវអោយអ្នកទាំងពីរ បែកគ្នា ដោយមិនអាចប្រកែកប្រឆាំងបានឡើយ ។ ចាប់ពីពេលនោះមក សម្លាញ់ដែលនៅរស់នោះ បានរស់នៅដោយកម្សត់ ត្រមង់ត្រមោច តែលតោលតែម្នាក់ឯង ដូចលលកឥតគូ ។ នារដូវស្រូវទុំ ស្រីក្រមុំ ដ៏កម្សត់នេះ បានទៅចាំចំការរបស់ខ្លួនកុំអោយសត្វស៊ីស្រូវ ។

ពេលដើរ ពិនិត្យជុំវិញចំការរួច នាងក៏ចូលបង្កាត់ភ្លើងនៅក្នុងខ្ទម

ដើម្បីបង្អើលដល់អស់សត្វព្រៃទាំងឡាយដែលចង់ស៊ីដំណាំនៅក្នុងចំការរបស់នាង ជាពិសេសទៀតចង់អោយព្រលឹងស្រូវនៅជិតដិតជាមួយនាងជារៀងរហូត (ជំនឿតាមប្រពៃណី) ។ ស្ថិតក្នុងបរិយាកាសដ៏ស្ងប់ស្ងាត់បែបនេះ នាងអង្គុយនៅក្នុងខ្ទមកំសត់តែម្នាក់ឯង គួរអោយស្រងេះ ស្រងោចណាស់ ។ នាងមិនបានលឺអ្វីឡើយក្រៅពីសំលេងសត្វបក្សា បក្សី យំចចេច ចចាចតាមព្រៃព្រឹក្សា ជើងភ្នំដងអូរនោះឡើយ ។ មានលលកត្រាំងមួយ ទំលើចុងឈើក្បែរខ្ទមនាង យំលឺស្រោល១ ហាក់ដូចជាគេមានទុក្ខដូចនាងដែរ ។ សំលេងនេះ បានបើកកកាយអារម្មណ៍របស់នាងអោយនឹកឃើញទាំងអស់នូវអនុស្សាវរីយ៍ពីអតីតកាល ។ ដោយនាងជាកូនកំព្រាផង កាលបានលឺលលកយំបែបនេះធ្វើអោយនាងកាន់តែក្តុកក្តួលក្នុងចិត្តយ៉ាងខ្លាំង នឹកស្រណោះខ្លួនដែលនៅកំព្រាឯកោតែម្នាក់ឯង ។ នាងលាន់មាត់តិច១ថា " ឱ ! សត្វលលក អើយ លឺអ្នកយំដូច្នេះ ធ្វើអោយខ្ញុំនឹកឃើញសម្លាញ់របស់ខ្ញុំ ! នឹកឃើញគ្រាដែលយើងរស់នៅជាមួយគ្នា ទៅព្រៃកាប់អុសជាមួយគ្នា ហើយពេលនេះហាក់បីដូចជាយើងបានរស់នៅជាមួយគ្នាទៀត ។

គិតកាន់តែច្រើន ចិត្តកាន់តែនឹក ទឹកភ្នែកចេះតែហូរជាតំណក់ៗ កាត់តាមផែនថ្ពាល់ទាំងគូរបស់នាងដោយឯងៗ។ នាងនិយាយទាំងខ្សឹបខ្សួលបន្ទោសខ្លួនឯងថា "ឱ! ខ្លួនខ្ញុំអើយ ខំកើតជាមនុស្សធ្វើអ្វី បើអភ័ព្វយ៉ាងនេះ ? គ្មានសាច់ញាតិ គ្មានមិត្តភក្តិជជែកលេង រស់នៅកំព្រាតែលតោលម្នាក់ឯងឥតកោះ ឥតត្រើយយ៉ាងនេះ។ បន្ទាប់ពីអង្គុយពិបាកចិត្តអស់រាប់សិបនាទីមក នាងក៏ក្រោកឡើងស្រវារចាប់ខ្សែត្រដោក ហើយទាញអោយលឺសូរ ដើម្បីបង្អើលសត្វដែលស៊ីស្រូវ។ គាត់ប្រឹងទាញខ្សែត្រដោកនោះ អស់ទំហឹងដៃ តែខ្សែនោះ បែរជាតឹងសន្ធឹង ហាក់ដូចជាមាននរណាម្នាក់មកទាញបន្តឹងខ្សែនោះមិនអោយរលាស់ ។ នាងនិយាយទាំងអួលណែនថា "តើនរណាជាអ្នកទាញបន្តឹងខ្សែនេះ ? ខ្ញុំជាកូនកំព្រាកំសត់ទុរគត គ្មានអ្នកណាអាចជួយរំលែកទុកខ្ញុំសោះ ឥឡូវនេះតើអ្នកណាធ្វើអោយខ្ញុំកាន់តែពិបាកចិត្តថែមទៀត ? "។ ក្រោយពីរអ៊ូរទាំហើយ នាងក៏ដើរទៅមើលខ្សែត្រដោកដល់កន្លែង ។ ពេលទៅដល់ទីនោះ ស្រាប់តែឃើញសម្លាញ់របស់នាងដែលទើបតែស្លាប់ទៅនោះ កំពុងឈរទាញបន្តឹងខ្សែត្រដោក ។ ឃើញភ្លាមនាងភ្ញាក់ព្រើត អូ ! គឺ សម្លាញ់ទេតើ !

ឯងមិនបានស្លាប់ចោលគ្នាទេឬ ? ហេតុអ្វីឯងមកនៅទីនេះទាញបន្តឹងខ្សែត្រដោកគ្នាទៅវិញ ? នាងបាននិយាយទៅកាន់សម្លាញ់ម្តងទៀតថាៈ សម្លាញ់អើយ ! ខ្ញុំនឹកឯងណាស់ ! តោះយើងទៅសំរាកនៅខ្ទមនោះសិន ! ឃើញឯងរស់ឡើងវិញដូច្នេះ ខ្ញុំសប្បាយចិត្តណាស់ ។ តាំងពីបាត់ឯងមក ជីវិតខ្ញុំឥតន័យសោះ បាយទឹកក៏មិនឃ្លាន ដេកក៏មិនលក់ ។ នាងដែលរស់ឡើងវិញនោះ និយាយទាំងទឹកភ្នែកថា "ខ្ញុំក៏នឹកឯងដូចគ្នាដែរ" ។ គេទាំងពីរនាក់អោបគ្នាបណ្តើរ យំបណ្តើរ ព្រោះគេរំភើបចិត្តខ្លាំងពេក ។ បន្ទាប់ពីដឹងសុខទុក្ខ គ្នាហើយ អ្នកទាំងពីរក៏នាំគ្នាសំដៅទៅខ្ទម ។ ពួកគេរកចៃអោយគ្នាបណ្តើរ ជជែកគ្នាលេងបណ្តើរ ប្រកបដោយភាពស្និទ្ធ ស្នាល ។

ពេលព្រះអាទិត្យ រៀបអស្តង្គត នាងសុំអោយសម្លាញ់ដែលរស់ឡើងវិញនេះត្រលប់ទៅផ្ទះជាមួយគ្នា ។ ប៉ុន្តែគួរអោយស្តាយណាស់សម្លាញ់របស់នាងមិនព្រមទៅជាមួយនាងទាល់តែសោះ ដោយនិយាយថា ៈសម្លាញ់ ទៅម្នាក់ឯងចុះ! ខ្ញុំនៅទីនេះហើយ ។ ដោយយល់ពីចិត្ត សម្លាញ់ នាងក៏មិនបង្ខំ ។ នាងក៏បង្ខំចិត្តទៅផ្ទះតែម្នាក់ឯងដោយនិយាយ ថាៈ

ថ្ងៃស្អែកខ្ញុំនឹងមកទីនេះទៀត សូមឯងមកលេងនឹងខ្ញុំផង ។ សម្លាញ់នាងតបថា "ចាស ! ខ្ញុំនឹងមកលេងនឹងឯងទៀត។ និយាយហើយគេក៏បែកគ្នាទៅ ។ ពេលទៅដល់ភូមិ នាងបានប្រញាប់ទៅប្រាប់ដំណឹងដល់ឪពុកម្តាយសម្លាញ់នាងភ្លាម " នែ៎ លោកតា អើយ ! ថ្ងៃនេះ ខ្ញុំឃើញសម្លាញ់ខ្ញុំរស់ឡើងវិញ "ឪពុករបស់នាងនោះថា "ចៅឯងនិយាយតែផ្តាស ! តាំងពីដើមមក តាមិនដែលឃើញមានមនុស្សណាដែលស្លាប់ហើយរស់ឡើងវិញនោះទេ។ នាងតបវិញថាៈ បើ តាមិនជឿក៏ហីចុះ តែម្សិលមិញនេះ ពួកខ្ញុំបាននៅជាមួយគ្នា ហើយរកថៃអោយគ្នាទៅវិញទៅមក និងលេងសើចជាមួយគ្នាយ៉ាងសប្បាយទៀតផង។ បើមិនជឿទេ ថ្ងៃស្អែកខ្ញុំនឹងសុំដូរប៉ានសំពត់ជាមួយគេរួចយកមកអោយលោកតា លោកយាយបានឃើញទាំងអស់គ្នា ។

លុះព្រឹកឡើងនាងក៏ស្រូតរូតទៅចំការនោះយ៉ាលឿន។ ពេលនោះសម្លាញ់របស់នាងបាន មកលេងនឹងនាងដូចថ្ងៃមុនដែរ។ ពួកគេអង្គុយជជែកគ្នាលេងសួរនាំពីនេះ ពីនោះជាច្រើន ។ ឆ្លៀតពេលនោះ នាងបាននិយាយទៅសំឡាញ់រស់ឡើងវិញថា :

"មកសំឡាញ់ យើងដូរប៉ានសំពត់គ្នា " នាងរស់ឡើងវិញសួរៈ ហេតុអ្វីបានជាឯងចង់ដូរប៉ានសំពត់ដូច្នេះ ?" នាងឆ្លើយថា " ដើម្បីទុកជាអនុស្សាវរីយ៍ ព្រោះឯងមិនព្រមទៅផ្ទះជាមួយខ្ញុំ។ អោយតែខ្ញុំបានឃើញប៉ានសំពត់នេះកាលណា គឺប្រៀបដូចជាខ្ញុំបានឃើញរូបឯងកាលនោះដែរ" ។ លឺ ដូច្នោះ សំឡាញ់របស់នាងក៏យល់ព្រម ។ លុះដល់ពេលល្ងាចនាងក៏បបួលសម្លាញ់របស់នាងត្រលប់ទៅផ្ទះម្តងទៀត តែនាងរស់ឡើងវិញបានបដិសេធនឹមិនព្រមទៅជាដាច់ខាត ។ នាងកំព្រាក៏ដើរត្រលប់ទៅផ្ទះវិញម្នាក់ឯងទៀត។ ពេលទៅដល់ផ្ទះ នាងក៏យកប៉ានសំពត់នោះ ទៅបង្ហាញអោយឪពុកម្តាយសម្លាញ់របស់ខ្លួនបានឃើញជាក់ស្តែង ។ ពេលដឹងថាជាប៉ានសំពត់របស់កូនខ្លួន ពួកគាត់ក៏ព្រមជឿហើយថែមទាំងនិយាយថា " ម្តេចក៏ចៅឯងមិននាំវាត្រលប់មកផ្ទះវិញ ? "ចា៎! លោកតា ខ្ញុំបានបបួលគេត្រលប់មកផ្ទះដែរ តែគេមិនព្រមសោះ តើអោយខ្ញុំធ្វើយ៉ាងម៉េចទៅ ?"

ឪពុកម្តាយគេប្រាប់នាងថា : បើអ៊ីចឹងថ្ងៃស្អែកនេះ ចៅឯងដាំបាយតំណើបអោយរីក ហើយពួកខ្ញុំនឹងចូលលាក់ខ្លួននៅក្នុងគុម្ពស្រូវក្បែរខ្ទមដើម្បីចាំលបមើល ។ បើមិនធ្វើដូច្នោះទេ យើងមិនឈ្នះគេបានឡើយ ។ លុះព្រឹកស្អែកឡើង នាងកំព្រាក៏ទៅចំការដូចសព្វដង ។ ពេលទៅដល់ចំការ នាងក៏ដាំបាយតំណើបអោយរីកស្អិត ដើម្បីអនុវត្តផែនការដែលឪពុកម្តាយនាងរស់បានប្រាប់ ។ តា យាយក៏លាក់ខ្លួននៅក្នុងគុម្ពស្រូវក្បែរខ្ទមនោះ ។ មួយស្របក់ក្រោយមក នាងរស់សំឡាញ់របស់នាងក៏បានមកដល់ ហើយគេនៅជាមួយគ្នាដូចថ្ងៃមុនដែរ រកចៃបណ្តើរនិយាយសន្ទនាគ្នាលេងបណ្តើរ យ៉ាងជក់ចិត្ត ។ រីឯឪពុកម្តាយនាងរស់កាលបានឃើញកូនសំណព្វចិត្តរបស់ខ្លួនរស់ឡើងវិញដូចនេះ ទាំងពីរនាក់ ប្តីប្រពន្ធមានការត្រេកអរជាពន់ពេក ។ បន្ទាប់ពីបានលបមើលកូនអស់រយះពេលរាប់សិបនាទីមក ទាំងពីរនាក់ប្តីប្រពន្ធក៏យកបាយតំណើបមកបាតលើដៃយ៉ាងស្អិត រួចស្រវ៉ាចាប់ក្របួចសក់កូនយ៉ាងជាប់ ។ នាងខំរើបំរះយ៉ាងអស់ពីកំលាំងតែមិនរួចសោះ ដោយសារពួកគាត់ចាប់សក់នាងវេញជាប់នឹងដៃជាមួយបាយតំណើបយ៉ាងស្អិតនោះ ។

ឪពុកម្តាយនាងបានលួងលោមនាងថា ៖ ល្អណាស់ ! ដែលកូនបានរស់ឡើងវិញដូច្នេះ ។ ពួកយើងនឹកកូនឯងខ្លាំងណាស់ នឹកស្ទើតែលេបបាយមិនចូល ។ នាងតបវិញថា "ខ្ញុំក៏នឹកពុកម៉ែណាស់ដែរ ។ ខ្ញុំចង់ត្រលប់ទៅផ្ទះយើងដែរ ប៉ុន្តែខ្ញុំខ្លាចក្រែងពេលខ្លះ ពុកម៉ែខឹងខ្ញុំ ហើយជេរខ្ញុំ ។ ព្រោះនៅពេលណាដែលគេជេរត្មះតិះដៀលខ្ញុំថា "អាខ្មោចអាបិសាច "នៅពេលនោះ រូបខ្ញុំនឹងប្រែក្លាយទៅជាខ្មោចភ្លាម ។ ហើយអ្នកទាំងពីរក៏គ្មានថ្ងៃណា បានឃើញរូបខ្ញុំដូចពេលនេះទៀតឡើយ" ។ អោយតែកូនព្រមទៅនៅជាមួយពុកម៉ែ ពុកម៉ែសន្យាថាមិននិយាយ (ជេរ) ដូច្នោះជាដាច់ខាត ព្រោះពេលនេះកូនបានប្រាប់អោយយើងដឹងជាមុនហើយ (សំដីឪពុកម្តាយ) ។ បន្ទាប់ពីបានស្តាប់ការអង្វររបស់ឪពុកម្តាយហើយ នាងរស់ក៏យល់ព្រមត្រលប់ទៅរស់នៅជាមួយឪពុកម្តាយដូចដើមវិញ ។ ហេតុតែនាងរស់មានសម្រស់ស្រស់ស្អាតគួរអោយស្រឡាញ់ នៅក្នុងភូមិនោះមិនទាន់បានមួយឆ្នាំផង ក៏មានកំលោះម្នាក់បានចាប់ចិត្តប្រតិពទ្ធ័ទៅលើនាង ហើយចង់ស្តីដណ្តឹងយកនាងធ្វើជាប្រពន្ធទៀតផង ។

ដោយស្រឡាញ់នាងរស់ពេក  បុរសនោះក៏ទៅសុំដល់ឪពុកម្ដាយដោយ ស្មោះត្រង់ថា " លោកតា លោកយាយ អើយ សូមអោយខ្ញុំបានធ្វើជា សមាជិកនៃគ្រួសារនេះអស់មួយជីវិតផង លោកតា លោកយាយទទួល ខ្ញុំធ្វើជា....ឪពុកម្ដាយស្រីតបវិញថា" បញ្ហានេះវាមិនជាការទាស់ខុស អីទេចៅ ! ហើយរឿងកូនប្រសានេះណា៎ ពួកខ្ញុំមិនចេះរើសអើងទេ ! សំខាន់អោយតែអ្នកទាំងពីរស្រឡាញ់គ្នាដោយស្មោះពិតប្រាកដទៅ បានហើយ ។  ម្យ៉ាងទៀតបើចៅឯងស្រឡាញ់កូនខ្ញុំពិតប្រាកដមែននោះ សូមចៅសន្យានឹងខ្ញុំរឿងមួយគឺថា ៈចៅឯងត្រូវមានចិត្តអត់ធ្មត់ដាច់ ខាតកុំជេរប្រម៉ាតនាងអោយសោះ ប្រយត្ន័បំផុតគឺមិនត្រូវជៀលនាង ថា "ស្រីខ្មោច ឬស្រីបិសាច" ឡើយ ។  បើពុំនោះទេ ពួកឯងរស់នៅជា មួយគ្នាមិនបានយូរឡើយ  ព្រោះនាងមិនមែនជាស្រីធម្មតានោះទេ ដរាបណាឯងហ៊ានជៀលនាងថា  "ស្រីខ្មោច ឬស្រីបិសាច" ដរាបនោះ នាងនឹងស្លាប់ក្លាយជាខ្មោចរហូត ។  អោយតែលោកតា លោកយាយ ព្រមអោយខ្ញុំរៀបការជាមួយនាង ខ្ញុំសុំធានាថា ៈខ្ញុំមិននិយាយ (ជេរ) ដូច្នោះជាដាច់ខាត ព្រោះពេលនេះ លោកទាំងពីរបានប្រាប់ពីអាថិ កំបាំងរបស់នាងអោយខ្ញុំដឹងអស់ហើយ (បុរសនោះតប) ។

ដោយសារបុរសនោះ ហ៊ានធានា ហើយព្រមទទួលនូវ បំរាមខាងលើ ឪពុកម្តាយនាងរស់ក៏យល់ព្រមអោយគេទាំងពីរនាក់ រៀបការជាមួយគ្នា ជាប្តីប្រពន្ធចាប់ពីពេលនោះទៅ ។

តាំងពីគេបានរៀបការមក ពួកគេបានរស់នៅជាមួយគ្នាយ៉ាងសុខសាន្ត រហូតដល់បានកូនស្រីមួយ ។ ថ្ងៃមួយនាងជាប្រពន្ធបានចុះងូតទឹកយូរមែនទែន ហើយកូននៅឯផ្ទះ យំយ៉ាងខ្លាំង ។ បុរសជាឪពុកខំលួងបំពេរកូនផង ស្រែកហៅប្រពន្ធផង តែមិនឃើញប្រពន្ធគាត់ឡើងមកសោះ ។ ដោយអាណិតកូនពេក បុរសជាឪពុកនោះ ក៏ខឹងមួម៉ៅក្តៅក្រហាយ យ៉ាងអន្ទះអន្ទែង ។ ទ្រាំមិនបាន គាត់ក៏ឆ្លោយសំដីថា "យកស្រីខ្មោច ស្រីបិសាចមកធ្វើជាប្រពន្ធពិតជាពិបាកមែន មិនដូចមនុស្សសោះ" និយាយមិនទាន់រួចពីមាត់ផង ភ្លាមនោះប្រពន្ធរបស់គាត់ក៏ដើរមក ដល់ផ្ទះ ស្រាប់តែដួលស្លាប់មួយរំពេច ក្លាយទៅជាខ្មោចរហូត ឥតរស់ ឡើងវិញឡើយ ។ នៅសល់តែប្តីនិងកូនស្រីតូចមួយគួរអោយអាសូរ ។ ចាប់ពីពេលនោះមក អ្នកស្រុកបាននាំគ្នាហៅកូននោះថាជា" ពូជខ្មោចរហូតដល់សព្វថ្ងៃនេះ "។

សៀវភៅរឿងព្រេងនិទានអំពី **"មនុស្សស្លាប់ហើយរស់វិញ"**

របស់ជនជាតិទំពួន ខេត្តរតនគិរី

បោះពុម្ពលើកទី១ ចំនួន ១០០ ក្បាល

ខែ មិនា ឆ្នាំ ២០០៦

បើចង់បានពតិមានបន្ថែមទៀត

សូមទាក់ទងមកតាមអាសយដ្ឋានខាងក្រោមនេះ :

**អង្គការសហការ** (ICC)

P.O BOX 612

ភ្នំពេញ កម្ពុជា

Tel : 023 215 200 / 023 213 310

ឬ

P.O BOX: 890003

បានលុង ខេត្តរតនគិរី

Tel : 075 974 029

A folk tale written in Tampuan language of Ratanakiri province, Kingdom of Cambodia. First printing,100 copies, March 2006. For more information or copies contact the address above.

ការបោះពុម្ពសៀវភៅនេះ អាចធ្វើទៅបានដោយមានការជួយថវិកាពី

រដ្ឋាភិបាលជប៉ុន ។

The printing of this book was made possible by a grant from Japanese government.

Prepared for first online distribution in March 2015 by

អង្គការសហការអន្តរជាតិកម្ពុជា
International Cooperation Cambodia
P.O. Box 612, Phnom Penh, Cambodia
Tel: 092-469-934 / 075-974-029
info@icc.org.kh
http://www.icc.org.kh

This work is dual licensed under either of these Creative Commons licenses:

- Attribution-ShareAlike 4.0 International License.(Cc-BY-SA) To view a copy of this license, visit http://creativecommons.org/licenses/by-sa/4.0/.
- Attribution-NonCommercial-ShareAlike (CC BY-NC-SA) To view a copy of this license, visit http://creativecommons.org/licenses/by-nc-sa/4.0/.

**You are free to:**

**Share** — copy and redistribute the material in any medium or format
**Adapt** — remix, transform, and build upon the material
for any purpose, even commercially.
The licensor cannot revoke these freedoms as long as you follow the license terms.

**Under the following terms:**

**Attribution** — You must give appropriate credit, provide a link to the license, and indicate if changes were made. You may do so in any reasonable manner, but not in any way that suggests the licensor endorses you or your use.

**ShareAlike** — If you remix, transform, or build upon the material, you must distribute your contributions under the same license as the original.

**No additional restrictions — You may not apply legal terms or technological measures that legally restrict others from doing anything the license permits.**